

ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែធ្នូ ឆ្នាំ២០១៦ លេខ៧

## សមិទ្ធផលឆ្នាំ២០១៦នៃកញ្ចប់ A ក្រោមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

ក្នុងឆ្នាំ២០១៦គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍-កញ្ចប់A ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស បានបញ្ចប់គោលដៅមួយចំនួនដើម្បីគាំទ្រដល់ក្រសួងសំខាន់ៗ--ក្រសួងបរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ដើម្បីបញ្ជ្រាបការបន្សុំាការប្រែប្រួលអាកាសធាតុទៅក្នុងផែនការកម្មវិធី និងគម្រោងវិនិយោគ។ ភាពជោគជ័យទាំងនេះត្រូវបានគូសបញ្ជាក់ដូចខាងក្រោម៖



- ចំនួនមន្ត្រីរដ្ឋាភិបាល សរុបចំនួនប្រមាណជិត១០០ នាក់ពីក្រសួងសំខាន់ទាំង៥ ត្រូវបានបណ្តុះបណ្តាលស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សុំាលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ កសិកម្មនិងធនធានទឹក។
- ក្រុមការងារបច្ចេកទេសវាយតម្លៃ ការអនុវត្តវិជ្ជមាន និងភាពប្រឈម នៅក្នុងខេត្តចំនួន៨ (ព្រៃវែង ពោធិ៍សាត់ បាត់ដំបង កំពង់ធំ កោះកុង មណ្ឌលគីរី ត្បូងឃ្មុំ និងកំពង់ឆ្នាំង)ចងក្រងជាករណីសិក្សាការបន្សុំាកសិកម្ម ធនធានទឹក និងការអភិវឌ្ឍទីក្រុង និងដឹកជញ្ជូន។
- ឯកសារសង្ខេបណែនាំការបន្សុំាផ្តែកលើវិស័យចំនួន៣ដែលត្រូវបានប្រមូលចងក្រងពីការចុះសិក្សានៅមូលដ្ឋាន និងសិក្សាស្វែងរកការអនុវត្តបន្សុំាល្អៗពីក្រៅប្រទេស ត្រូវបានរៀបចំជាសេចក្តីព្រាង និងធ្វើការសហការជាមួយក្រសួងពាក់ព័ន្ធ។ ឯកសារទាំងនេះគ្រោងនឹងបញ្ចប់ និងផ្សព្វផ្សាយឱ្យទូលំទូលាយនៅឆ្នាំ២០១៧។
- សេចក្តីប្រកាសស្វែងរកការចែករំលែកការអនុវត្តបន្សុំារបស់ជនជាតិដើមភាគតិច និងជាលក្ខណៈប្រពៃណី ដោយប្រមូលពីប្រភពផ្សេងៗរួមមានគ្រឹះស្ថានអប់រំ សង្គមស៊ីវិល និងការសិក្សាស្រាវជ្រាវរបស់ក្រុមការងារTA កំពុងត្រូវបានចងក្រង និងគ្រោងផ្សព្វផ្សាយជាឯកសារបោះពុម្ពនៅក្នុងត្រីមាសទី១ឆ្នាំ២០១៧។

- កិច្ចប្រជុំសម្របសម្រួលកម្មវិធី SPCR ចំនួន២ដង ត្រូវបានរៀបចំដើម្បីពង្រឹងការសម្របសម្រួលក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងគម្រោងវិនិយោគ។

**ការសិក្សាលម្អិតពីលទ្ធភាពគម្រោងបន្សាំអាទិភាពត្រូវបានរៀបចំឡើង**

- ផ្តែកលើការវាយតម្លៃការអនុវត្តវិជ្ជមាន និងអវិជ្ជមាន ព្រមទាំងការរៀនសូត្រពីចំណេះដឹងពីជនជាតិភាគតិច គម្រោងបានកំណត់ទស្សនាទានគម្រោងទាំង៦ស្តីពីការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការអភិវឌ្ឍកសិកម្ម ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការដឹកជញ្ជូន។ ការសិក្សាលម្អិតពីទស្សនាទានគម្រោងទាំង៦សម្រាប់មូលនិធិអាកាសធាតុនឹងត្រូវបានវិភាគនៅឆ្នាំខាងមុខនេះ។
- របាយការណ៍ស្តីពីឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ ដែលអាចអនុវត្តដើម្បីវាយតម្លៃ និងរៀបចំផែនការគម្រោង និងកម្មវិធីនៅក្នុងបរិបទកម្ពុជាត្រូវបានចងក្រង ចែករំលែក និងបានកែសម្រួលបញ្ចប់រួចរាល់តាមមតិដែលទទួលបានពីអ្នកពាក់ព័ន្ធ។

**ឯកសារចំណេះដឹងការបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយ**

- សិក្ខាសាលាចែករំលែកចំណេះដឹង ស្តីពី ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជាដែលផ្តោតលើការអនុវត្តបន្សាំរបស់ជនជាតិដើមភាគតិច និងជាលក្ខណៈប្រពៃណីត្រូវបានរៀបចំឡើងក្នុងកិច្ចសហការជាមួយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងអង្គការផ្លែនអន្តរជាតិដោយមានអ្នកចូលរួមចំនួនប្រមាណ១០០នាក់នៅខេត្តព្រះសីហនុដើម្បីឆ្លុះបញ្ចាំងពីមេរៀនបទពិសោធន៍ និងការលើកទិសដៅនាពេលអនាគតក្នុងការបញ្ជ្រាបការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។



## កញ្ចប់ C ៖ យេនឌ័រ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ នៅថ្នាក់ក្រោមជាតិ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ជាមួយអ្នកពាក់ព័ន្ធលើយុទ្ធសាស្ត្រ ចំនួន៣

កញ្ចប់C៖យេនឌ័រការតាមដានត្រួតពិនិត្យនិងវាយតម្លៃនិងការបញ្ជ្រាបនៅថ្នាក់ក្រោមជាតិនៃគម្រោងTA៨១៧៩៖ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើយុទ្ធសាស្ត្រចំនួន៣៖

- ការណែនាំគម្រោង
- ផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ
- ការបញ្ជ្រាបយេនឌ័រ ទៅក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល និងក្រសួងធនធានទឹក និងឧតុនិយម



កម្មវិធីបានរៀបចំនៅខេត្តសៀមរាបពីថ្ងៃទី១៤-១៥ ខែធ្នូឆ្នាំ២០១៦។ អ្នកចូលរួមមានចំនួន៨១នាក់ (ច្រើនជាង ៥០%ជាស្ត្រី)ពីក្រសួងគោលដៅ និងមន្ទីរ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភ្នាក់ងារអន្តរជាតិ។ សិក្ខាសាលានេះត្រូវបានអញ្ជើញចូលរួមបើកក្រោមអធិបតីភាពលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

នៅក្នុងសន្ទរកថាបើក លោកជំទាវ អ៊ឹង កន្ថាផាវី បានគូសបញ្ជាក់ថាការបញ្ជ្រាបយេនឌ័រទៅក្នុងគម្រោងវិនិយោគការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុទៅក្នុងគ្រប់វិស័យ គឺជាអាទិភាពគោលដៅរបស់ក្រសួងកិច្ចការនារី។ លោកជំទាវបានមានប្រសាសន៍សង្កត់ធ្ងន់ថា ការបញ្ជ្រាបយេនឌ័រក្នុងការផ្តួចផ្តើមការប្រែប្រួលអាកាសធាតុគឺអាចចូលរួមកាត់បន្ថយភាពក្រីក្រ និងទទួលបានគោលដៅដែលមាននិរន្តរភាព។ កិច្ចពិភាក្សាក្នុងចំណោមអ្នកចូលរួម បានចេញជាសកម្មភាពសំខាន់ៗមួយចំនួនសម្រាប់គម្រោងជំនួយបច្ចេកទេសនេះ ដើម្បីអនុវត្តនៅឆ្នាំខាងមុខ រួមមាន៖

- សម្របសម្រួលកិច្ចពិភាក្សាជាមួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ និងមន្ត្រីពាក់ព័ន្ធពីក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសុខាភិបាល និងក្រសួងសាធារណការ និងដឹកជញ្ជូន
- ពិនិត្យមើលឡើងវិញនិងធ្វើបច្ចុប្បន្នភាពឯកសារនិងគោលនយោបាយនានាដើម្បីគាំទ្រដំណើរការនៃការបញ្ជ្រាបយេនឌ័រ
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រចាំបាច់ និងព្រឹត្តិការណ៍សំខាន់ៗដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ
- ជានាការអនុវត្តត្រូវបានតាមដានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពដល់ក្រុមការងារសម្របសម្រួលដើម្បីឱ្យប្រសើរឡើងនាពេលអនាគត។

តាមរយៈសិក្ខាសាលានេះ ក្រុមការងារបច្ចេកទេសមានផែនការកែសម្រួលផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុដើម្បីអនុវត្ត និងពិគ្រោះជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយមក្រសួងសុខាភិបាល និង ក្រសួងសាធារណការនិងដឹកជញ្ជូនលើបច្ចុប្បន្នភាពផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួងទាំងនេះ ដើម្បីគូសបញ្ជាក់ពីបញ្ហាជាក់លាក់ការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការនីមួយៗ។

## នាយកដ្ឋានប្រែប្រួលអាកាសធាតុ បង្ហាញ និងធ្វើតេស្តសាកល្បងឧបករណ៍បង្រួញមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុដល់ក្រសួងពាក់ព័ន្ធ

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ឧបករណ៍បង្រួញមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ" នៅថ្ងៃទី១៦ខែធ្នូ ឆ្នាំ២០១៦។ សិក្ខាសាលាបណ្តុះបណ្តាលនេះ ត្រូវបានដឹកនាំដោយឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធីSPCR និង ឯកឧត្តម ជួប ប៉ារីស៍ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ អ្នកចូលរួមអញ្ជើញមកពីក្រសួងដែលអនុវត្តគម្រោងវិនិយោគក្រោមកម្មវិធីSPCR ក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរ។




គោលបំណងសំខាន់របស់សិក្ខាសាលាបណ្តុះបណ្តាលនេះ គឺបង្ហាញ និងធ្វើតេស្តសាកល្បងបង្រួញមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ និងប្រមូលមតិយោបល់របស់អ្នកចូលរួម ដើម្បីធ្វើឱ្យតម្រូវការទិន្នន័យ តាមវិស័យកាន់តែល្អប្រសើរឡើង។ ឧបករណ៍នេះត្រូវបានបង្កើតឡើងសម្រាប់បម្រើឱ្យអ្នកធ្វើផែនការអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីវិភាគ និងប្រើប្រាស់ព័ត៌មានការប្រែប្រួលអាកាសធាតុសម្រាប់ការរៀបចំ និងការគ្រប់គ្រងគម្រោងរបស់រដ្ឋាភិបាល។

បន្ទាប់ពីចូលរួមសិក្ខាសាលាបណ្តុះបណ្តាល លោកស្រី អ៊ាម សុខជា មន្ត្រីព័ត៌មានភូមិសាស្ត្រមកពីក្រសួងសាធារណការ និងដឹកជញ្ជូន បានឱ្យដឹងថា "នេះជាឧបករណ៍ដ៏មានប្រយោជន៍។ យើងអាចប្រើវាដើម្បីទាញយកព័ត៌មានដែលត្រូវការ ដើម្បីគ្រប់គ្រងហានិភ័យអាកាសធាតុ ដូចជាការធ្វើផែនទីការព្យាករណ៍អាកាសធាតុរហូតដល់ឆ្នាំ២០៥០"។ អ្នកចូលរួមភាគច្រើនឯកភាពលើការប្រើប្រាស់ឧបករណ៍នេះ សម្រាប់ការបំពេញការងាររបស់ខ្លួន ហើយបានស្នើឱ្យដាក់បញ្ចូលនូវទិន្នន័យនៅកម្រិតឃុំផងដែរ។ ការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលបែបនេះទៀត នៅឆ្នាំក្រោយក៏ជាសំណូមពររបស់អ្នកចូលរួមផងដែរ។

នៅពេលឧបករណ៍នេះត្រូវបានរៀបចំរួចរាល់ នឹងត្រូវបានដាក់បង្ហោះលើគេហទំព័រ www.camclimate.gov.kh ហើយអាចត្រូវបានប្រើប្រាស់តាមវិស័យ ដោយរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងធ្វើផែនការអភិវឌ្ឍន៍ ហើយសាធារណៈជនក៏អាចប្រើប្រាស់បានផងដែរ។ ទោះបីយ៉ាងណាដើម្បីរៀបចំបង្កើតឧបករណ៍នេះឱ្យរួចរាល់សម្រាប់ការប្រើប្រាស់ វាចាំបាច់ត្រូវបានស្នើសុំការបង្កើតជាក្រុមការងារដែលមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ឧបករណ៍នេះនឹងអនុញ្ញាតឱ្យអ្នកជំនាញតាមវិស័យផ្លាស់ប្តូរពីវិធីសាស្ត្រចងក្រងទិន្នន័យព័ត៌មានពីការប្រែប្រួលអាកាសធាតុតាមគម្រោងឱ្យទៅជាវិធីសាស្ត្រជាលក្ខណៈប្រព័ន្ធដែលអាចស្វែងរកបាននៅលើបណ្តុំព័ត៌មានតែមួយ។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ បានមានប្រសាសន៍នៅក្នុងសន្ទរកថាបើកវគ្គបណ្តុះបណ្តាលនេះថា ឧបករណ៍បម្រួញមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រ សម្រាប់ការប្រែប្រួលអាកាសធាតុគឺមានសារៈសំខាន់ណាស់សម្រាប់អ្នកធ្វើផែនការ និងអ្នករៀបចំគោលនយោបាយដើម្បីយល់ដឹងពីការព្យាករណ៍ការប្រែប្រួលអាកាសធាតុសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តលើបទអន្តរាគមន៍។ ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាអន្តរវិស័យ និងតម្រូវឱ្យវិភាគទិន្នន័យវិទ្យាសាស្ត្រដែលបំពាក់នូវឧបករណ៍ទំនើបៗដោយមន្ត្រីពាក់ព័ន្ធត្រូវមានសមត្ថភាពបច្ចេកទេសវិទ្យាសាស្ត្រផងដែរ។




## ក្រុមការងារសម្របសម្រួលកម្មវិធី SPCR ពិគ្រោះយោបល់លើសូចនាករបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលមានប្រសិទ្ធភាព

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធីSPCR បានដឹកនាំកិច្ចប្រជុំលើកទី៥ របស់ក្រុមការងារសម្របសម្រួលកម្មវិធីSPCR កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦។ កិច្ចប្រជុំនេះជាឱកាសដ៏មានសារៈសំខាន់ សម្រាប់គម្រោងវិនិយោគនានា និងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ស្តីពីការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP)ចែករំលែកព័ត៌មានអំពីវឌ្ឍនភាព និងការពិភាក្សាលើបញ្ហានិងភាពប្រឈម ដើម្បីរួមគ្នាធ្វើឱ្យការអនុវត្តនូវគម្រោង/កម្មវិធីកាន់តែល្អប្រសើរឡើង។




ប្រធានបទទី១គឺទាក់ទងនឹងសូចនាករសម្រាប់វាស់ប្រសិទ្ធភាពការបន្សាំ។ គម្រោង MCRDP ដែលកំពុង ធ្វើការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅតាមក្រសួង(កញ្ចប់A) និងនៅថ្នាក់ក្រោមជាតិ (កញ្ចប់C) និងអង្គការសង្គមស៊ីវិល (កញ្ចប់B) បានចែករំលែកវិធីសាស្ត្រក្នុងការវាស់ភាពធន់នឹងអាកាសធាតុ។

កញ្ចប់A (ក្រុមហ៊ុនICEM និងក្រុមហ៊ុនFraser Thomas Partners)បានបង្ហាញវិធីសាស្ត្រក្នុងការកំណត់សូចនាករដើម្បីវាស់ប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែង។ សូចនាករគួរតែផ្តោតលើវិធានការបន្សាំពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងទ្រព្យសកម្មរបស់ក្រសួងសំខាន់ៗដែលបម្រើលើធនធានទឹក កសិកម្ម ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងជនបទ (ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន)។ វិធីសាស្ត្រដែលបានលើកឡើងគឺប្រៀបធៀបការខូចខាត ឬបាត់បង់ដែលមាន និងគ្មានការបន្សាំ--ជាឧទាហរណ៍ការប្រៀបធៀបផ្លូវរបស់រដ្ឋដែលធន់ និងមិនធន់នឹងអាកាសធាតុកន្លងមក។ ប្រព័ន្ធនឹងគ្រប់គ្រងភាពត្រឹមត្រូវនៃព្រឹត្តិការណ៍អាកាសធាតុ ដើម្បីវាយតម្លៃវិធានការណាខ្លះដែលធន់នឹងអាកាសធាតុដែលធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធកាន់តែធន់។



គម្រោង MCRDPកញ្ចប់B (អង្គការភ្លែន អន្តរជាតិ) បានពិពណ៌នា ឧទាហរណ៍សូចនាករដែលកំពុងត្រូវបានប្រើដោយអង្គការសង្គមស៊ីវិលដែលទទួលបានកញ្ចប់ថវិកា ដើម្បីវាស់ពីលទ្ធផលនៅកម្រិតសហគមន៍។ គម្រោង MCRDP កញ្ចប់C(អង្គការ UN Habitat) បានបង្ហាញពីសូចនាករដែលកំពុងត្រូវបានប្រើដោយគម្រោងវិនិយោគក្រោមកម្មវិធីSPCR និងសម្រាប់កម្មវិធីSPCRទាំងមូល។ ក្រសួងផែនការដោយមានសេវាបច្ចេកទេស MCRDPកញ្ចប់C កំពុងសិក្សាលម្អិតដើម្បីដាក់បញ្ចូលវិធានការភាពធន់នឹងអាកាសធាតុទាំងនេះទៅក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃជាតិ។

កិច្ចពិភាក្សាបានលើកឡើងចំណុចសំខាន់ៗ ដើម្បីកំណត់សូចនាករប្រសិទ្ធភាពលើការបន្សាំ ដូចជាការបង្កើនសមត្ថភាពដើម្បីវាស់ប្រសិទ្ធភាពនៅថ្នាក់ក្រោមជាតិ និងចាត់តាំងតួនាទីនិងការទទួលខុសត្រូវច្បាស់លាស់តាមក្រសួងវិស័យ និងតាមកម្រិតផ្សេងៗរបស់រដ្ឋាភិបាល។

បន្ទាប់ពីពិភាក្សាលើសូចនាករ គម្រោងវិនិយោគក្រោមកម្មវិធីSPCR បានរាយការណ៍ពីវឌ្ឍនភាព របស់គម្រោង។ បើទោះជាគម្រោងវិនិយោគភាគច្រើនកំពុងស្ថិតនៅដំណាក់កាលចាប់ផ្តើមការអនុវត្តក៏ដោយ អ្នកចូលរួមកិច្ចប្រជុំបានបង្ហាញសង្ខេបពាក់ព័ន្ធវឌ្ឍនភាពសំខាន់ៗដូចជាម៉ូដែលហានិភ័យ ទឹកជំនន់ និងគ្រោះរាំងស្ងួត ការបណ្តុះបណ្តាលពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយផ្អែកលើសហគមន៍ ការរៀបចំបទដ្ឋានហេដ្ឋារចនាសម្ព័ន្ធ និងការបណ្តុះបណ្តាលកសិករពីកសិកម្មវៃឆ្លាត។ មកដល់ពេលនេះ គម្រោងវិនិយោគទាំង៧ ដែលអនុវត្តដោយក្រសួងស្ថាប័នពាក់ព័ន្ធកំពុងត្រូវបានចងក្រងលិខិតបទដ្ឋានច្បាប់ការធ្វើលទ្ធកម្មសម្រាប់សាងសង់។

## ការសិក្សាពីការអនុវត្តរបស់ជនជាតិដើមភាគតិចដើម្បីបង្កើនចំណេះដឹងពីភាពធន់នឹងអាកាសធាតុ



សហគមន៍ជាច្រើននៅកម្ពុជា បានប្រមូលផ្តុំចំណេះដឹងជាលក្ខណៈប្រពៃណី និងការអនុវត្តដែលចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ សហគមន៍ជនជាតិដើមភាគតិចពឹងផ្អែកលើធនធានធម្មជាតិ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ហើយចាំបាច់សម្របទៅនឹងការប្រែប្រួលអាកាសធាតុ និងការគំរាមបរិស្ថានផ្សេងៗទៀត។ ជាលទ្ធផល ការអនុវត្តលក្ខណៈប្រពៃណីយូរៗទៅ បានក្លាយជាវិធានការដែលឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ក្រោមគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ នាយកដ្ឋានប្រែប្រួលអាកាសធាតុកំពុងធ្វើការចងក្រងចំណេះដឹងស្តីពីការអនុវត្ត

ជាលក្ខណៈប្រពៃណីសម្រាប់ភាពធន់នឹងអាកាសធាតុ។ គោលបំណងនៃការផ្តួចផ្តើមនេះគឺដើម្បីធ្វើឱ្យកាន់តែយល់ដឹងពីរបៀបនៃការអនុវត្តដែលអាចដាក់បញ្ចូលនៅក្នុងគោលនយោបាយបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកម្មវិធីនានា។ កាលពីឆ្នាំមុន អ្នកជំនាញរបស់គម្រោងMCRDP និងមន្ត្រីបច្ចេកទេសរដ្ឋាភិបាល បានសិក្សាស្រាវជ្រាវ និងចងក្រងការអនុវត្តជាលក្ខណៈប្រពៃណីនៅកន្លែងផ្សេងៗគ្នាក្នុងវិស័យកសិកម្ម ធនធានទឹក និងការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។ គម្រោងបានចេញផ្សាយសេចក្តីប្រកាសដល់អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំ និងវិស័យឯកជន ដើម្បីស្នើសុំចែករំលែកការសិក្សាស្រាវជ្រាវរបស់ពួកគេស្តីពីការអនុវត្តបន្សាំរបស់ជនជាតិដើមភាគតិច និងជាលក្ខណៈប្រពៃណី។



ការអនុវត្តបន្សាំផ្សេងៗ ត្រូវបានចងក្រងតាមរយៈការផ្តួចផ្តើមនេះ។ ឧទាហរណ៍រួមមានការអភិរក្សព្រៃឫស្សី ការត្រងទឹកភ្លៀង ការប្រើប្រាស់ទឹកប្រប់ធម្មជាតិដែលគ្រប់គ្រង ដោយសហគមន៍ បច្ចេកទេសការចិញ្ចឹមសត្វដែលមាននិរន្តរភាព ការជ្រើសរើសពូជស្រូវរយៈពេលខ្លី និងបច្ចេកទេស សាងសង់ស្ពានជាលក្ខណៈប្រពៃណី។ ការចងក្រងការអនុវត្តរបស់ជនជាតិដើមភាគតិច ត្រូវបានផ្សព្វផ្សាយដល់អ្នករៀបចំគោលនយោបាយ ដៃគូរដ្ឋាភិបាល អ្នកធ្វើផែនការ និង អង្គការមិនមែនរដ្ឋាភិបាលនៅសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី “ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា” ដែលរៀបចំឡើងនៅខេត្តព្រះសីហនុនៅថ្ងៃទី២៩-៣០ខែវិច្ឆិកា។ សិក្ខាសាលាចែករំលែកចំណេះដឹងនេះបានបង្ហាញវិធានការដែលចំណាយតិច ងាយស្រួលសម្រប អនុវត្តដោយស្ត្រី និងបុរស និងអាចអនុវត្តតាម។ ក្នុងនោះក៏បានបង្ហាញពីសារៈសំខាន់នៃការបង្កើតគោលនយោបាយ និងកម្មវិធីនានាដែលលើកកម្ពស់ការអនុវត្តរបស់ជនជាតិដើមភាគតិចដើម្បីដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ដោយសារការប្រែប្រួលអាកាសធាតុកាន់តែញឹកញាប់ និងធ្ងន់ធ្ងរ ការអនុវត្តរបស់ជនជាតិដើមភាគតិច មិនអាចចំណាយលើសកម្មភាពបន្សាំលើសពីប្រាក់ចំណូលរបស់ពួកគេទេ ដែលប្រការនេះជាភាពប្រឈមរបស់សហគមន៍។ ប៉ុន្តែការរៀនសូត្រពីការអនុវត្តជាលក្ខណៈប្រពៃណី និងការចងក្រងបញ្ចូលចំណេះដឹងទាំងនេះព្រមជាមួយការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីនឹងផ្តល់នូវដំណោះស្រាយថ្មីៗដើម្បីដោះស្រាយភាពប្រឈមនៃការអភិវឌ្ឍភាពធន់នឹងអាកាសធាតុ។

## ការចែករំលែកចំណេះដឹងស្តីពីការអនុវត្តជាលក្ខណៈប្រពៃណីសម្រាប់ភាពធន់នឹងអាកាសធាតុ




នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រុមក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព ដោយមានការជួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី នៃគម្រោងហិរញ្ញប្បទាន សហប្រតិបត្តិការបច្ចេកទេស ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងអង្គការភ្លែន អន្តរជាតិនៅខេត្តព្រះសីហនុ នៅថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ បានសហការគ្នារៀបចំ “សិក្ខាសាលាចែករំលែកចំណេះដឹង” ដែលផ្តោតយ៉ាងទូលំទូលាយ ពីអន្តរាគមន៍ការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍។




សិក្ខាសាលានេះត្រូវបានអញ្ជើញចូលរួមតំណាង មកពីស្ថាប័នរដ្ឋាភិបាល តំណាងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ ១២០នាក់ ក្នុងគោលបំណងចែករំលែកចំណេះដឹងក្នុងការអនុវត្ត និងគាំទ្រការអនុវត្តបន្ស៊ាំ ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍នៅកម្ពុជា។ នៅក្នុងសន្ទរកថាបើកសិក្ខាសាលា ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានបញ្ជាក់ថា ការចែករំលែកចំណេះដឹងគឺជាអាទិភាពរបស់កម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ហើយវាជាវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលអាចធ្វើឡើងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។



សិក្ខាសាលានេះ បានបង្ហាញជាឧទាហរណ៍នៃការអនុវត្តបន្ស៊ាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលកំពុងត្រូវបានអនុវត្តក្នុងវិស័យ និងតាមភូមិសាស្ត្រតំបន់នានានៅកម្ពុជា។ ផ្នែកសំខាន់នៃសិក្ខាសាលាចែករំលែកចំណេះដឹងនេះ ជាការសិក្សាពីការអនុវត្តជាលក្ខណៈប្រពៃណីដើម្បីបង្កើនភាពធន់នឹងអាកាសធាតុ។ ផ្នែកនេះបានបង្ហាញឱ្យឃើញពីសហគមន៍ផ្សេងៗនៅកម្ពុជាដែលលើកឡើងពីចំណេះដឹងរបស់ជនជាតិភាគតិចលើការអនុវត្តសំខាន់ៗសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ សហគមន៍ជនជាតិដើមភាគតិចពឹងផ្អែកលើធនធានធម្មជាតិសម្រាប់ការរស់នៅ និងការអនុវត្តបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងកិច្ចគាំពារបរិស្ថានផ្សេងៗទៀត។ ជាលទ្ធផល ការអនុវត្តរបស់ជនជាតិដើមភាគតិចយូរៗទៅក្លាយជាវិធានការដែលអាចអនុវត្តដើម្បីឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) កំពុងធ្វើការចងក្រងចំណេះដឹងស្តីពីការអនុវត្តជាលក្ខណៈប្រពៃណីសម្រាប់ភាពធន់នឹងអាកាសធាតុ។ គោលបំណងនៃការផ្តួចផ្តើមនេះគឺដើម្បីធ្វើឱ្យកាន់តែយល់ដឹងពីរបៀបនៃការអនុវត្តដែលអាចដាក់ជាគោលនយោបាយបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងកម្មវិធីនានា។ កាលពីឆ្នាំមុន អ្នកជំនាញឯកទេសរបស់គម្រោងMCRDP និងមន្ត្រីបច្ចេកទេសរដ្ឋាភិបាល បានសិក្សាស្រាវជ្រាវ និងចងក្រងការអនុវត្តជាលក្ខណៈប្រពៃណីដែលមកពីកន្លែងផ្សេងៗគ្នាក្នុងវិស័យកសិកម្ម ធនធានទឹក និងការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។ ក្នុងខែកញ្ញាឆ្នាំ២០១៦ គម្រោងបានចេញផ្សាយសេចក្តីប្រកាសដល់អង្គការមិនមែនរដ្ឋាភិបាលអង្គការសង្គមស៊ីវិល គ្រឹះស្ថានអប់រំ និងវិស័យឯកជនដើម្បីស្នើសុំចែករំលែកការសិក្សាស្រាវជ្រាវរបស់ពួកគេស្តីពីការអនុវត្តបន្ស៊ាំរបស់ជនជាតិដើមភាគតិច និងជាលក្ខណៈប្រពៃណី ដើម្បីផ្សព្វផ្សាយចំណេះដឹងទាំងនេះឱ្យកាន់តែទូលំទូលាយ។

ការសិក្សាស្រាវជ្រាវរបស់គម្រោងMCRDP និងតាមសេចក្តីប្រកាស បានចេញជាលទ្ធផលក្នុងការចងក្រងការអនុវត្តផ្សេងៗបានជាច្រើន។ ជាឧទាហរណ៍ដែលបានធ្វើបទបង្ហាញក្នុងសិក្ខាសាលាចែករំលែកចំណេះដឹងនៅខេត្តព្រះសីហនុគឺការ

អភិរក្សព្រៃឫស្សីរបស់ជនជាតិដើមភាគតិចពួងក្នុងខេត្តមណ្ឌលគីរី។ ដីកសិកម្មរបស់ជនជាតិដើមភាគតិចពួងស្ថិតនៅជិតព្រៃឫស្សី ដូច្នេះដើមឈើបានក្លាយជារបងធម្មជាតិដែលការពារដំណាំរបស់ពួកគេពីខ្យល់ព្យុះ ឬខ្យល់កន្ត្រាក់។ ក្រុមមនុស្សចាស់ៗបានបង្រៀនអ្នកផ្សេងៗពីបច្ចេកទេសសម្រាប់ការប្រមូលផលឫស្សីដោយមាននិរន្តរភាព ដោយការពារដល់ការហូរច្រោះនិងបាក់ដីទីជម្រាល ដែលនាំឱ្យពួកគេអាចទាញយកផលប្រយោជន៍ពីធនធានធម្មជាតិដើម្បីជួសជុលផ្ទះ ឬសាងសង់ដោយមិនធ្វើឱ្យខូចខាតតំបន់ព្រៃឈើ។ ទាក់ទងនឹងការពង្រីកកសិឧស្សាហកម្ម ចំណេះដឹងនៃការគ្រប់គ្រងដែលមាននិរន្តរភាពព្រៃឫស្សី និងការការពារតំបន់វាលស្មៅត្រូវបានធ្លាក់ចុះ។ ការអភិរក្ស និងការពង្រីកបន្ថែមនៃការអនុវត្តការប្រើប្រាស់ឫស្សីជាសម្ភារៈសាងសង់ដែលអាចបន្តប្រើប្រាស់ឡើងវិញ និងការការពារធនធានធម្មជាតិសម្រាប់ដាំដំណាំ ជាវិធានការបន្សាំមួយដើម្បីផ្សព្វផ្សាយគោលនយោបាយការប្រែប្រួលអាកាសធាតុកម្ពុជា និងកម្មវិធីនានា។




ជាឧទាហរណ៍ផ្សេងទៀតបានបង្ហាញពីការត្រងទឹកភ្លៀងទុកក្នុងរដូវវស្សា ការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍ បច្ចេកទេសចិញ្ចឹមសត្វដែលមាននិរន្តរភាព ការជ្រើសរើសពូជស្រូវដែលមានរយៈពេលខ្លី និងបច្ចេកទេសជាលក្ខណៈប្រពៃណីសាងសង់ស្ពាន។ បទបង្ហាញដែលបានលើកឡើងរួមមានវិធានការដែលចំណាយតិច ងាយស្រួលសម្រប អនុវត្តដោយស្ត្រី និងបុរស និងការឆ្លើយតបដែលអាចអនុវត្តបាន។ គោលនយោបាយប្រែប្រួលអាកាសធាតុកម្ពុជាជំរុញអង្វែង និងចាំបាច់ត្រូវពិចារណាពីការដាក់បញ្ចូលចំណេះដឹងការអនុវត្តរបស់ជនជាតិដើមភាគតិចជាមួយការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗដើម្បីស្វែងរកដែលល្អជាងគេសម្រាប់ការបន្សាំ។ ការប្រមូលចងក្រងបង្កើតនូវមនុស្សចាស់ៗរបស់ជនជាតិដើមភាគតិចក្នុងការប្រមូលដកស្រង់បទពិសោធន៍អំពីជីវិតជាក់ស្តែងគួរតែត្រូវបានប្រមូលផ្តុំ និងធ្វើការសិក្សាបន្ថែមទៀតដោយការពិគ្រោះផ្ទាល់ និងធ្វើបទបង្ហាញនូវពេលអនាគត។

## ទស្សនកិច្ចចុះពិនិត្យសកម្មភាពការងារគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើសហគមន៍

កាលពីថ្ងៃទី២១ខែតុលា ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និង ឯកឧត្តម ប៊ុន សារឿន អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងមន្ត្រីជំនាញបានចុះពិនិត្យសកម្មភាពគម្រោងដែលកំពុងអនុវត្ត ដោយអង្គការសង្គមស៊ីវិល នៃគម្រោងយន្តការគាំទ្រសង្គមស៊ីវិលតាមរយៈការផ្តល់ហិរញ្ញប្បទានខ្នាតតូច ពីអង្គការក្លែនអន្តរជាតិដែលគាំទ្រដោយមូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី។



ដំណើរទស្សនកិច្ចនេះក្នុងគោលបំណងគឺដើម្បីពង្រឹងកិច្ចសហការរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើការងារបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដែលផ្អែកលើសហគមន៍និងពិនិត្យផែនការសកម្មភាព ដែលបានលើកឡើងសម្រាប់សកម្មភាពបន្ស៊ាំនិងផ្តល់អនុសាសន៍នានាដើម្បីធ្វើយ៉ាងណាពង្រឹងភាពធន់របស់សហគមន៍ងាយរងគ្រោះនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

## ក. ពិនិត្យដំណើរការអនុវត្តការងាររបស់សហគមន៍ព្រៃឈើនៅឃុំក្រាំងសេរី ខេត្តកំពង់ស្ពឺ (២១ ខែតុលា ២០១៦)

ក្រុមការងារបានចុះពិនិត្យទីតាំងសហគមន៍ព្រៃឈើក្រាំងសេរី ឃុំក្រាំងសេរី ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលមានសកម្មភាពជីកស្រះមួយកន្លែងនៅទីទំនាប ជម្រៅ៤ម៉ែត្រ ទទឹង២៣ម៉ែត្រ និងបណ្តោយ១០៣ម៉ែត្រ។ ស្រះនេះអាចផ្ទុកទឹកបានប្រមាណជា៩.០០០ម៉ែត្រគូប និងតបណ្តាញទុយោចែកចាយទឹក ប្រវែង៨.០០០ម៉ែត្រជូនប្រជាជនចំនួន៤ភូមិ (ភូមិក្រាំងច្រេស ភូមិក្រាំងសេរី ភូមិត្រពាំងក្រឡឹង និងភូមិក្រាំងស្យា)មានចំនួន៤៣០គ្រួសារឱ្យបានប្រើទឹកពីស្រះនេះនៅរដូវរាំងស្ងួត និងបានបញ្ច្រាបការជ្រើសរើសពូជដែលបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមការងារបានណែនាំឱ្យខិតខំអនុវត្តសកម្មភាពឱ្យបានទាន់ផែនការដែលបានគ្រោងទុក ការពារព្រៃឈើ និងអភិរក្សសត្វព្រៃ ដែលអាចឈានទៅបង្កើតកន្លែងទេសចរណ៍ធម្មជាតិសម្រាប់ភ្ញៀវចូលទស្សនា និងអាចទទួលបានចំណូលបន្ថែមជួយដល់ការងារអភិវឌ្ឍន៍ដោយចីរភាពសម្រាប់ប្រជាសហគមន៍ទូទាំងឃុំនាពេលអនាគត។

## ខ. ការចុះពិនិត្យដំណើរការអនុវត្តការងារអង្គការលើកកម្ពស់ធនធានសហគមន៍ដើម្បីអភិវឌ្ឍន៍ (CRID) ក្នុងខេត្តត្បូងឃ្មុំ

ដំណើរទស្សនកិច្ចបានចុះទៅភូមិរវីលលើ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ដែលជាទីតាំង អង្គការ CRID សហការជាមួយអង្គការ Plan International Cambodia បានបណ្តុះបណ្តាលតំណាងប្រជាជនចំនួន១៥នាក់មកពី៤ភូមិឱ្យយល់ដឹងពីរបៀបគ្រប់គ្រងប្រើប្រាស់ធុងចម្រោះទឹកស្អាត និងចែកចាយធុងចម្រោះ។ សកម្មភាពនេះ ជនបង្គោលទាំងនោះនឹងធ្វើការផ្សព្វផ្សាយដល់សមាជិកសហគមន៍ទាំង៤ដើម្បីប្រើប្រាស់ធុងចម្រោះតាមបច្ចេកទេស និងទទួលបាននូវសុខភាពល្អ ។

គណៈប្រតិភូ បុគ្គលិកអង្គការក្លែនអន្តរជាតិ បុគ្គលិកអង្គការ CRID និងតំណាងសហគមន៍ ក៏បានពិភាក្សាលើសកម្មភាពដែលគ្រោងនឹងអនុវត្តក្នុងត្រីមាសបន្ទាប់គឺការស្តារប្រឡាយប្រវែងប្រហែលជា៤០០ម៉ែត្រ ដើម្បីផ្គត់ផ្គង់ទឹកដល់ប្រជាកសិករក្នុងភូមិទាំង៤ក្នុងការបូមទឹកសម្រាប់ការស្រោចស្រពបានគ្រប់គ្រាន់។ ជាការឆ្លើយតប ក្រុមការងារបានណែនាំអំពីទិសដៅនៃការអភិវឌ្ឍដោយចីរភាពដែលរួមមានការស្តារប្រព័ន្ធស្រោចស្រពដើម្បីឱ្យកសិករមានលទ្ធភាពទឹកស្រោចស្រពគ្រប់គ្រាន់ជាពិសេសការពារបញ្ហាគ្រោះរាំងស្ងួត។ លើសពីនេះ ក្រុមការងារក៏បានជម្រុញ និងលើកទឹកចិត្តដល់ប្រជាជនឱ្យបង្កើនការបន្ស៊ាំពូជដំណាំ និងដាំដុះដំណាំធន់នឹងការប្រែប្រួលអាកាសធាតុ។

គណៈប្រតិភូក៏បានបង្ហាញពីការខិតខំប្រឹងប្រែងផ្តល់ការសហការ និងការគាំទ្រខ្ពស់ដល់សកម្មភាពដែលបានលើកឡើង និងជម្រុញឱ្យមានការជួយគាំទ្រពីអាជ្ញាធរ ឃុំ ស្រុក និងខេត្តផងដែរ។

## គ. ការចុះពិនិត្យដំណើរការអនុវត្តការងាររបស់អង្គការ HURREDO ខេត្តសៀមរាប

ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៦ គណៈប្រតិភូ និងក្រុមការងារបច្ចេកទេសបានពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ មន្ត្រីបច្ចេកទេសថ្នាក់ស្រុកពីគម្រោងសាងសង់ទំនប់ស្នាក់ទឹក និងចុះពិនិត្យ ទីតាំងសម្រាប់ការសាងសង់ទំនប់ និងទ្វារទឹក ដែលបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ នៅស្រុកសូទ្រនិគម ឃុំចាន់ស ភូមិជាំ និងភូមិច្បារក្នុងខេត្តសៀមរាប ដែលជាគម្រោងអនុវត្តដោយអង្គការ HURREDO សហការជាមួយអង្គការ Plan International Cambodia និងគណៈកម្មការក្រុមប្រឹក្សាឃុំ។ ក្រុមការងារ និងក្រុមប្រឹក្សាឃុំ ព្រមទាំងអាជ្ញាធរមូលដ្ឋាន បានបន្តចុះពិនិត្យទីកន្លែងសម្រាប់សាងសង់ទ្វារទឹក និងជួសជុលទំនប់ទឹក និងសិក្សាពីផលប៉ះពាល់របស់គម្រោង។

ក្រុមការងារបានជួបសំណេះសំណាល ជាមួយប្រជាពលរដ្ឋដែលជាក្រុមសន្សំប្រាក់ នៅភូមិឈូក ឃុំខ្នារពោធិ៍ និងបានចុះពិនិត្យ ស្រះចិញ្ចឹម និងរក្សាត្រីពូជមេ កសិករគំរូចិញ្ចឹមមាន់ និងដាំដំណាំផ្សេងៗ តាមគោលការណ៍បច្ចេកទេសដើម្បីបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងវិធានការកាត់បន្ថយគ្រោះមហន្តរាយដែលអាចកើតឡើងជាយថាហេតុ។ ក្រុមការងារ បានផ្តល់ជាយោបល់បន្ថែមលើការងារបច្ចេកទេស និងលើកទឹកចិត្តដល់ប្រជាកសិករឱ្យបន្តការខិតខំប្រឹងប្រែងធ្វើផលិតកម្ម ដើម្បីទទួលបាន

ចំណូលបន្ថែម ក៏ដូចជាកាត់បន្ថយការចំណាយក្នុងគ្រួសារ ។ ដោយឡែកការងារសន្សំពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាជាប្រភពទុនដែលកសិករឬសមាជិកអាចខ្ចី និងសន្សំបានងាយស្រួល និងទាន់ពេលវេលាទៀតផង។ បន្ថែមពីនេះទៀតកម្មវិធីសន្សំនេះបានបណ្តុះគំនិត និងបង្កើនចំណេះដឹងពីការអនុវត្ត កសិករនឹងទទួលបាននូវបទពិសោធន៍ពីរបៀបកត់ត្រាការងារគ្រប់គ្រង រៀបចំផែនការធុរៈកិច្ច និងមុខរបរសម្រាប់គ្រួសារនីមួយៗ ដែលទាំងនេះជាចំណុចដែលសហគមន៍យើងត្រូវការសិក្សាបន្ថែមទៀត។ ជារួមក្រុមការងារបានផ្តល់យោបល់បន្ថែមដល់អង្គការដៃគូ និងសហគមន៍ឱ្យសហការល្អថែមទៀតជាមួយអាជ្ញាធរដែនដីដូចជា៖



**១. សហគមន៍ព្រៃឈើក្រាំងសេរី៖** ត្រូវខិតខំបន្តការអនុវត្តរាល់សកម្មភាពដែលបានលើកឡើង ការពារព្រៃឈើអភិរក្ស សត្វព្រៃ ការងារនេះនឹងទទួលបាននូវការទាក់ទាញភ្ញៀវទេសចរណ៍ សម្រាប់កម្មវិធីទេសចរណ៍ធម្មជាតិ ដែលអាចទាក់ទាញចំណូលបន្ថែមហើយក៏ជាការរួមចំណែកការអភិវឌ្ឍន៍សហគមន៍ប្រកបដោយនិរន្តភាព។

**២. អង្គការលើកកម្ពស់ធនធានសហគមន៍ដើម្បីអភិវឌ្ឍន៍៖** ត្រូវបន្តគាំទ្រសហគមន៍បន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដូចជា ការស្វែងរកពូជធន់ សួនបន្លែ និងដាំដំណាំធន់នឹងអាកាសធាតុ ។ ក្រុមការងារក៏បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែង ផ្តល់ការសហការក្នុងការអនុវត្តគម្រោងជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងតំបន់។

**៣. អង្គការអភិវឌ្ឍន៍ធនធានមនុស្ស និងសេដ្ឋកិច្ចជនបទ៖** ដោះស្រាយបញ្ហាការបង្ហូរទឹកកខ្វក់ពីកសិដ្ឋានចិញ្ចឹមជ្រូកមួយកន្លែងដែលមានទីតាំងនៅក្នុងភូមិជាំ ឃុំចាន់ស ស្រុកសូត្រនិគមន៍ ខេត្តសៀមរាប។ ក្រុមការងារបច្ចេកទេសលើកទឹកចិត្តឱ្យខំដាំដុះបន្លែ ចិញ្ចឹមមាន់ និងស្រូវ ដើម្បីបង្កើនចំណូលសម្រាប់គ្រួសារ។ ការសន្សំប្រាក់ពិតជាកម្មវិធីដែលល្អ ព្រោះវាជាប្រភពទុនដែលសមាជិកអាចខ្ចីបានងាយស្រួល និងទាន់ពេលពេលដែលត្រូវការ។ ម្យ៉ាងវិញទៀត កម្មវិធីសន្សំនេះ វាក៏បានបង្កើនចំណេះដឹងនិងជំនាញលើការងារកត់ត្រា ផែនការ ការគ្រប់គ្រងមុខរបរ និងពង្រឹងមុខរបរចិញ្ចឹម ជីវិតផងដែរ។

ជារួមទស្សនកិច្ចចុះត្រួតពិនិត្យការងារនេះ បានផ្តល់នូវភាពកក់ក្តៅដល់អង្គការដៃគូ សហគមន៍ ជាពិសេស បានពង្រឹងកិច្ចសហការរវាងអង្គការសង្គមស៊ីវិល និងមន្រ្តីរដ្ឋាភិបាលទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍ផងដែរ ។ ម្យ៉ាងវិញទៀត ក្រុមការងារបានផ្តល់ជាគំនិត ចំណេះដឹង និងបច្ចេកទេសបន្ថែមលើអ្វីដែលអង្គការដៃគូ និងកសិករ ដែលកំពុងចូលរួមអភិវឌ្ឍន៍ភាពធន់នឹងអាកាសធាតុនៅថ្នាក់ឃុំ ស្រុកដែលជួយជម្រុញឱ្យពួកគាត់យល់ដឹងកាន់តែច្បាស់ពីការងារបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍ និងដកស្រង់មេរៀនបទពិសោធន៍ល្អៗក្នុងការបញ្ចូលនៅក្នុងគោលនយោបាយតាមរយៈអ្នកធ្វើផែនការគ្រប់គ្រង និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។


ព័ត៌មានបន្ថែម៖

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី

លោក មាស សុផល នាយកដឹកនាំកម្មវិធី

លោក អ៊ូ ច័ន្ទជាទិត្យ ប្រធានគ្រប់គ្រងកម្មវិធី

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

នាយកដ្ឋានប្រែប្រួលអាកាសធាតុ

អគារមរតកតេជោ ឡូតិ៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧

អ៊ីម៉ែល៖ adbspcrta8179@gmail.com

គេហទំព័រ៖ http://www.spcrcambodia.org/kh/